# ដំណឹងមរណភាព

៚៙៚

- ឯកឧត្តម ព្រុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងលោកជំទាវ ព្រមទាំងបុត្រធីតា
- លោកជំទាវវេជ្ជបណ្ឌិត ព្រុំ ឆោមសាយឿន
- លោក ចាន់ តារា និងលោកស្រី ព្រមទាំងបុត្រ
- លោក ចាន់ វាសនា និងលោកស្រី ព្រមទាំងបុត្រធីតា
- លោក ព្រុំ សំខាន់ និងលោកស្រី ព្រមទាំងបុត្រធីតា
- លោកស្រី ព្រុំ សីមា និងលោក សុខ សម្បត្តិ ព្រមទាំងបុត្រធីតា
- លោក ចាន់ គន្លេត និងលោកស្រី លឹម រចនា ព្រមទាំងបុត្រ
- លោកស្រី ចាន់ គន្ធី និងលោក ទិត វុទ្ធី ព្រមទាំងបុត្រធីតា
- លោក ចាន់ សិទ្ធិ

មានទុក្ខជាទម្ងន់ដោយ **ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត ចាន់ ស៊ីវ៉ាន់ថា អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល** ដែលត្រូវជាប្អូន ជាស្វាមី ជាបង ជាឪពុក និងជាជីតា បានទទួលមរណភាពកាលពីថ្ងៃសៅរ៍ ៨រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០២០ វេលាម៉ោង ០០:៣០នាទី ក្នុងជន្មាយុ ៦៧ឆ្នាំ ដោយរោគាពាធ។

សព **ឯកឧត្តម ចាន់ ស៊ីវ៉ាន់ថា** ត្រូវបានតម្កល់ទុកធ្វើបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនានៅគេហដ្ឋានលេខ ៤២ ផ្លូវលីលី បុរីហាយតិចលុចសារី (ទល់មុខវត្តនិរោធរង្សី) សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ពិធីបូជាសព នឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ១០រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៩ព្រឹក នាឈាបនដ្ឋានវត្តជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី មិត្តភ័ក្ត និងបងប្អូនញាតិមិត្តជិតឆ្ងាយនៃសព អញ្ជើញចូលរួមពិធីបុណ្យ ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធនៃសព និងចាប់មគ្គផលតាមកំលាំងសទ្ធាជ្រះថ្លារៀងៗខ្លួន៕